COUNTY OF LOS ANGELES
Public Health

# សេចក្តីណែនាំសម្រាប់ប្រតិបត្តិការមជ្ឈមណ្ឌលការពាររលកកម្តៅ ក្នុងអំឡុងពេលជំងឺ COVID-19

កម្តៅខ្លាំង គឺជាការគំរាមកំហែងដ៏ធំមួយដល់សុខភាពសាធារណជន។ ការដាក់ឱ្យត្រូវនឹងកម្តៅខ្លាំងអាចបណ្តាលឱ្យមានបញ្ហាសុខភាពជាច្រើនប្រភេទ រាប់ចាប់ពីការអស់កម្លាំងទូទៅ រហូតដល់ឈឺសាច់ដុំ ថែមទាំងរហូតដល់បញ្ហាក្តៅខ្លាំងខ្សោះជាតិទឹក (heat stroke) ដែលជាបញ្ហាដែលគំរាមកំហែងដល់អាយុជីវិតទៀតផង។ មជ្ឈមណ្ឌលការពាររលកកម្តៅត្រូវបានរៀបចំឡើងដើម្បីផ្តល់ជំនួយ និងការការពារក្នុងអំឡុងពេលមានកម្តៅខ្លាំង។

សុខភាព និងសុវត្ថិភាពរបស់បុគ្គលិកនិងភ្ញៀវនៅមជ្ឈមណ្ឌលការពាររលកកម្តៅ គឺជាចំណុចសំខាន់បំផុតសម្រាប់ពួកយើង។ នៅពេលដែល *សេចក្តីបង្គាប់អំពីការឆ្លើយតបជាមួយគ្នានៅកន្លែងធ្វើការនិង ចំពោះសហគមន៍ (Responding Together at Work and in the Community Order)* របស់មន្ត្រីសុខាភិបាលនៅតែមានប្រសិទ្ធិភាព សេចក្តីណែនាំខាងក្រោមត្រូវបានផ្តល់ជូន ដើម្បីបើកដំណើរការមជ្ឈមណ្ឌលការពាររលកកម្តៅដោយសុវត្ថិភាពនៅពេលមានកម្តៅឡើងខ្ពស់។

## A. សកម្មភាពសុវត្ថិភាពផ្សេងៗនៅតាមទីតាំង

- ☐ ចូរបិទផ្លាកសញ្ញាផ្សព្វផ្សាយនៅតាមច្រកចូលសាធារណៈនីមួយៗនៃមជ្ឈមណ្ឌលការពាររលកកម្តៅ ដើម្បីជូនដំណឹងដល់បុគ្គលិក និងសាធារណជនទាំងអស់ ថាពួកគេមិនគួរចូលទេ ប្រសិនបើពួកគេមានក្អក គ្រុនក្តៅ ឬរោគសញ្ញាផ្សេងទៀតនៃជំងឺ COVID-19 ឬកំពុងតែអនុវត្តតាមសេចក្តីបង្គាប់នៃការឱ្យនៅដាច់ដោយឡែក ឬការឱ្យធ្វើចត្តាឡីស័កយ៉ាងសកម្ម ហើយមនុស្សគ្រប់គ្នាត្រូវតែពាក់ម៉ាស់ខណៈពេលដែលនៅក្នុងមជ្ឈមណ្ឌលការពាររលកកម្តៅ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការឡើយ។ គំរូផ្លាកសញ្ញាអាចរកបាននៅលើគេហទំព័រនេះ៖[publichealth.lacounty.gov/acd/ncorona2019/BestPractices/#signage](http://publichealth.lacounty.gov/acd/ncorona2019/BestPractices/#signage)។
- ☐ ប្រសិនបើអាចធ្វើទៅបាន សូមផ្តល់ជូននូវទីតាំងការពាររលកកម្តៅដទៃទៀតសម្រាប់អ្នកដែលមានរោគសញ្ញានៃជំងឺ COVID-19។ នេះគួរតែជាបន្ទប់ដាច់ដោយឡែកនៅក្នុងមជ្ឈមណ្ឌលការពាររលកកម្តៅសម្រាប់មនុស្សម្នាក់ៗដែលមានរោគសញ្ញា។
- ☐ សូមចាត់វិធានការណ៍ តាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើនកុះករនៅក្នុងមជ្ឈមណ្ឌលការពាររលកកម្តៅ ដោយកាត់បន្ថយភាពកកកុញនៅតាមច្រកចូលទៅ និងចេញពីទីកន្លែងនោះ ហើយបែងចែកកន្លែងអង្គុយ និងរៀបចំឱ្យមានភាពងាយស្រួលក្នុងការចូលប្រើបន្ទប់ទឹក។
- ☐ ចូរដាក់ទឹកអនាម័យលាងសម្អាតដៃនៅច្រកចូល និងទីតាំងទូទៅនានា ហើយធានាថាមានដាក់សាប៊ូ និងទឹកដែលអាចរកបាននៅក្នុងកន្លែងនោះ។ បន្ទប់ទឹក ដែលជាធម្មតាបើកបម្រើការជូនដល់សាធារណជន គួរតែបន្តបើកបម្រើការជូនដល់សាធារណជនដដែល។
- ☐ ចូរបិទផ្លាកសញ្ញាដោយមានពីធីការបង្ការការចម្លងមេរោគតាមផ្លូវដង្ហើម ការលាងសម្អាតដៃ និងដំណឹងអំពីការពាក់ម៉ាស់ នៅទូទាំងទីតាំងនោះ។ គំរូផ្លាកសញ្ញាអាចរកបាននៅលើគេហទំព័រនេះ៖ [publichealth.lacounty.gov/acd/ncorona2019/BestPractices/#signage](http://publichealth.lacounty.gov/acd/ncorona2019/BestPractices/#signage)។
- ☐ ប្រសិនបើមជ្ឈមណ្ឌលការពាររលកកម្តៅអនុញ្ញាតឱ្យពិសាអាហារ និងភេសជ្ជៈនៅខាងក្នុងអគារ ចូររៀបចំកន្លែងអង្គុយដែលបានកំណត់ច្បាស់លាស់ ហើយត្រូវបានប្រើជាពិសេសសម្រាប់ភ្ញៀវដែលកំពុងពិសាអាហារ និងភេសជ្ជៈឱ្យឆ្ងាយពីកន្លែងអង្គុយផ្សេងទៀត។ ទីតាំងដែលអនុញ្ញាតឱ្យពិសាអាហារ និងភេសជ្ជៈនៅខាងក្នុងអគារ ត្រូវបានចាត់ទុកថាជាទីតាំងដែលប្រឈមនឹងហានិភ័យខ្ពស់ជាង ពីព្រោះមនុស្សទាំងអស់ រួមទាំងអ្នកដែលបានចាក់និងមិនបានចាក់ថ្នាំបង្ការរួច គឺនៅខាងក្នុងអគាររយៈពេលយូរ ហើយអាចដោះម៉ាស់របស់ពួកគេចេញដើម្បីពិសាអាហារ ឬភេសជ្ជៈទៀតផង។ ភ្ញៀវដែលប្រើទីតាំងដែលបានកំណត់នេះគួរតែអាចរក្សាគម្លាត 6 ហ្វីតពីអ្នកដទៃពេលកំពុងពិសាអាហារ ឬភេសជ្ជៈ។ ផ្លាកសញ្ញានៅក្នុងទីតាំងនេះគួរតែរំលឹកដល់ភ្ញៀវថា ពួកគេត្រូវតែអង្គុយជាប់នៅពេលពិសាអាហារ ឬភេសជ្ជៈ ហើយពួកគេអាចដោះម៉ាស់របស់ពួកគេចេញបានតែនៅពេលដែលពួកគេកំពុងពិសាអាហារ ឬភេសជ្ជៈ យ៉ាងសកម្មតែប៉ុណ្ណោះ។ គ្រប់ពេលទាំងអស់ក្រៅពីនេះ ភ្ញៀវត្រូវតែពាក់ម៉ាស់របស់ពួកគេ។
- ☐ នៅកន្លែងដែលអាចធ្វើទៅបាន សូមចាត់វិធានការណ៍ដើម្បីបង្កើនខ្យល់បក់ចេញចូលនៅក្នុងមជ្ឈមណ្ឌលការពាររលកកម្តៅ។ សូមប្រាកដថា ប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់រួមគ្នា

(HVAC) នៃមជ្ឈមណ្ឌលការពាររលកកម្ដៅគឺនៅល្អ និងមានដំណើរការជម្មតា។ ពិចារណាតំឡើងម៉ាស៊ីនសម្អាតខ្យល់ដែលមានប្រសិទ្ធិភាពខ្ពស់ហើយអាចចល័តបាន ធ្វើឱ្យតម្រងខ្យល់របស់អគារប្រសើរឡើង ហើយឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ពីខាងក្រៅ និងខ្យល់ចេញចូលនៅគ្រប់ទីតាំងធ្វើការ។ កាត់បន្ថយចំនួនមនុស្សនៅក្នុងទីតាំងដែលមានខ្យល់បក់ចេញចូលខាងពីខាងក្រៅមកតិចតួច។ សូមមើល [សេចក្ដីណែនាំស្ដីទីសម្រាប់ប្រព័ន្ធខ្យល់បក់ចេញចូល តម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុងអគារ](#) របស់ CDPH សម្រាប់ព័ត៌មានបន្ថែម។

- ☐ ចូរចាត់តាំងបុគ្គលិកឱ្យចុះឈ្មោះភ្ញៀវដោយស្ម័គ្រចិត្តក្នុងមួយថ្ងៃៗ (សូមមើលឧបសម្ព័ន្ធ A)។ ការរៀបចំឱ្យមានបញ្ជីឈ្មោះភ្ញៀវប្រចាំថ្ងៃអាចមានប្រយោជន៍ ប្រសិនបើមានករណីវិជ្ជមាននៃជំងឺ COVID-19 ហើយមជ្ឈមណ្ឌលការពាររលកកម្ដៅចាំបាច់ត្រូវទាក់ទងទៅបុគ្គលដែលមានទំនាក់ទំនងនឹងករណីនេះ ដើម្បីជូនដំណឹងដល់ពួកគេអំពីការប្រឈមមុខនឹងការប៉ះពាល់ទៅនឹងមេរោគរបស់ពួកគេ។ បុគ្គលិកក៏គួរតែរក្សាចំនួនភ្ញៀវដែលបដិសេធមិនចុះឈ្មោះចូលផងដែរ។ ចូររក្សាកំណត់ត្រាអំពីបុគ្គលិក និងអ្នកស្ម័គ្រចិត្តដែលស្ថិតនៅមជ្ឈមណ្ឌលការពាររលកកម្ដៅជារៀងរាល់ថ្ងៃ។
- ☐ សូមអនុវត្តតាមសេចក្ដីណែនាំផ្សេងៗសម្រាប់ ការសម្អាត និងសម្លាប់មេរោគចំពោះទីតាំងសហគមន៍របស់ មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) និង ការសម្អាតទីតាំង ប្រសិនបើនរណាម្នាក់ឈឺ។
- ☐ សកម្មភាពផ្សេងទៀតដែលបានបង្គាប់ដោយអ្នកគ្រប់គ្រងទីតាំងនោះ៖

  ______________________________________________

## B. សកម្មភាពសុវត្ថិភាពផ្សេងៗសម្រាប់បុគ្គលិក

- ☐ មជ្ឈមណ្ឌលការពាររលកកម្ដៅត្រូវតែត្រួតពិនិត្យបុគ្គលិក អ្នកស្ម័គ្រចិត្ត អ្នកលក់ អ្នកម៉ៅការ និងអ្នកធ្វើការផ្សេងទៀតចំពោះរោគសញ្ញានៃជំងឺ COVID-19។ បុគ្គលិកទាំងអស់គួរតែត្រូវបានត្រួតពិនិត្យរករោគសញ្ញានៅពេលចាប់ផ្ដើមវេនការងាររបស់ពួកគេ។ ជម្រើសសម្រាប់ការត្រួតពិនិត្យរួមមាន ដោយឱ្យបុគ្គលិកវាយតម្លៃរោគសញ្ញាផ្ទាល់ខ្លួនមុនពេលមកមជ្ឈមណ្ឌល ដោយការប្រើផ្លាកសញ្ញានៅច្រកចូលកន្លែងធ្វើការ ឬដោយបំពេញការត្រួតពិនិត្យនៅនឹងកន្លែងជារៀងរាល់ថ្ងៃ ដើម្បីបន្ថែមដំណឹងដែលថាបុគ្គលិកដែលមានរោគសញ្ញានៃជំងឺ COVID-19 និងអ្នកដែលស្ថិតនៅក្រោមសេចក្ដីបង្គាប់នៃការឱ្យនៅដាច់ដោយឡែក ឬការឱ្យធ្វើចត្តាឡីស័ក មិនគួរចូលកន្លែងធ្វើការទេ។ សូមមើល publichealth.lacounty.gov/media/coronavirus/docs/business/EntryScreening.pdf សម្រាប់គំរូបែបបទនៃការត្រួតពិនិត្យពេលចូល។
- ☐ បុគ្គលិកត្រូវបានណែនាំឱ្យនៅផ្ទះ ប្រសិនបើពួកគេមានអារម្មណ៍មិនស្រួលខ្លួន។ បុគ្គលិកដែលត្រូវបានរាយការណ៍ថា ឬបង្ហាញថាមានរោគសញ្ញាជំងឺនឹងត្រូវបានស្នើសុំឱ្យចាកចេញ និងស្វែងរកការព្យាបាលដែលសមស្រប។ ត្រូវប្រាកដថាអ្នកដែលមានជំងឺ COVID-19 អនុវត្តតាមការណែនាំនានាអំពីការដាក់ខ្លួនឯងឱ្យ នៅដាច់ដោយឡែក។ បុគ្គលិកដែលជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនឹងករណីត្រូវតែ ធ្វើចត្តាឡីស័ក លុះត្រាតែមានការលើកលែង ។ ត្រូវគ្រប់គ្រងការប៉ះពាល់ជំងឺ COVID-19 នៅកន្លែងធ្វើការនៅពេលដែលគេដឹងថាបុគ្គលិកម្នាក់បានឆ្លងមេរោគដោយកំណត់ និងផ្ដល់ព័ត៌មានអំពីមនុស្សដែលមានការប៉ះពាល់ទៅនឹងមេរោគនោះឱ្យបានឆាប់បំផុត។ រៀបចំឱ្យមានផែនការក្នុងការផ្ដល់ការធ្វើតេស្តដល់បុគ្គលិកដែលអាចនឹងប៉ះពាល់ទៅនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។ សូមយោងទៅលើគេហទំព័រ ការឆ្លើយតបចំពោះជំងឺ COVID-19 នៅកន្លែងធ្វើការ សម្រាប់ព័ត៌មានបន្ថែម។
- ☐ បុគ្គលិកត្រូវពាក់ម៉ាស់គ្រប់ពេលវេលា លើកលែងតែនៅពេលពិសាអាហារ ឬភេសជ្ជៈក្នុងពេលសម្រាកនៅតាមទីតាំងដែលបានកំណត់។ សូមមើលទំព័រស្ដីពីម៉ាស់របស់ខោនធី LA សម្រាប់ព័ត៌មានបន្ថែម៖ publichealth.lacounty.gov/acd/ncorona2019/masks/។
- ☐ បុគ្គលិកត្រូវបានជំរុញឱ្យរក្សាគម្លាតយ៉ាងតិច 6 ហ្វីតពីបុគ្គលិកដទៃ និងភ្ញៀវផ្សេងទៀត ប៉ុន្តែមិនតម្រូវចាំបាច់ឡើយ។

- ☐ បុគ្គលិកតម្រូវឱ្យលាងសម្អាតដៃ ឬប្រើទឹកអនាម័យលាងសម្អាតដៃ មុនពេល/បន្ទាប់ពីប្តូរវេន មុន/ក្រោយពេលសម្រាក និងបន្ទាប់ពីសកម្មភាពណាមួយដូចនេះ៖ ប្រើបន្ទប់ទឹក ពិសាអាហារ ចូលឬចាកចេញពីទីតាំង ហើយបន្ទាប់ពីប៉ះផ្ទៃដែលមានការប៉ះពាល់ច្រើន (ដៃទ្វារ ឧបករណ៍បញ្ជាទូរទស្សន៍ បង្កាន់ដៃ ។ល។) ដោយប្រើទឹកអនាម័យលាងសម្អាតដៃ ឬសាប៊ូនិងទឹក ដែលអាចរកបាននៅទីកន្លែងនោះ។
- ☐ បុគ្គលិកគួរតែត្រូវបានជំរុញឱ្យសម្រាកពិសាអាហារនៅខាងក្រៅអគារ ឬនៅតែម្នាក់ឯងនៅក្នុងការិយាល័យដែលបិទជិត តាមដែលអាចធ្វើទៅបាន។ ប្រសិនបើបុគ្គលិកត្រូវតែពិសាអាហាររបស់ពួកគេនៅក្នុងអគារ ពួកគេគួរតែពិសាពេលកំពុងអង្គុយ និងមានគម្លាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ ប្រសិនបើទីតាំងពិសាអាហារនោះនៅក្នុងអគារ។
- ☐ បុគ្គលិកត្រូវបានណែនាំឱ្យធ្វើតាមនីតិវិធីទូទៅសម្រាប់អ្នកដែលមានទុក្ខព្រួយ ឬជួបប្រទះភាពអាសន្ន ដោយទូរស័ព្ទទៅលេខ 911។
- ☐ បុគ្គលិកគួរតែទទួលបានច្បាប់ចម្លងនៃសេចក្តីណែនាំនេះ។

## C. សកម្មភាពសុវត្ថិភាពផ្សេងៗសម្រាប់ភ្ញៀវ

- ☐ ភ្ញៀវត្រូវបានជូនដំណឹងថាមិនឱ្យចូលទីតាំង ប្រសិនបើពួកគេឈឺ ឬត្រូវអនុវត្តតាមសេចក្តីបង្គាប់នៃការឱ្យនៅដាច់ដោយឡែក ឬការឱ្យធ្វើចត្តាឡីស័ក តាមរយៈផ្លាកសញ្ញាដែលបានបិទផ្សព្វផ្សាយ។
  - → *បុគ្គលិកនឹងណែនាំមនុស្សគ្រប់រូបដែលកំពុងរាយការណ៍ថា ឬបង្ហាញរោគសញ្ញានានានៃជំងឺ ឱ្យចាកចេញ និងស្វែងរកការព្យាបាលសមស្រប ប្រសិនបើចាំបាច់ ឬបើអាចធ្វើទៅបាន សូមណែនាំមនុស្សនោះទៅកាន់ទីតាំងមជ្ឈមណ្ឌលការពាររលកកម្តៅដទៃទៀត សម្រាប់បុគ្គលដែលមានរោគសញ្ញា។*
- ☐ តម្រូវឱ្យភ្ញៀវពាក់ម៉ាស់គ្រប់ពេល។
  - → *បុគ្គលិកនឹងណែនាំដល់មនុស្សគ្រប់គ្នាដែលមិនអនុវត្តតាមច្បាប់ថាតម្រូវឱ្យពាក់ម៉ាស់ជាចាំបាច់។*
  - → *ប្រសិនបើអាចធ្វើទៅបាន បុគ្គលិកនឹងផ្តល់ម៉ាស់ដល់អ្នកដែលមកដល់ដោយមិនមានយកម៉ាស់មកជាមួយ។*
- ☐ ភ្ញៀវត្រូវបានជំរុញឱ្យរក្សាចម្ងាយយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ ប៉ុន្តែមិនចាំបាច់តម្រូវឡើយ។
- ☐ ភ្ញៀវអាចរកទឹកអនាម័យលាងសម្អាតដៃ សាប៊ូ និងទឹកបាននៅក្នុងទីតាំងនេះ។
  - → *បុគ្គលិកនឹងរំលឹកភ្ញៀវឱ្យលាងសម្អាតដៃ ឬប្រើទឹកអនាម័យលាងសម្អាតដៃឱ្យបានញឹកញាប់ រួមទាំងនៅពេលចូល និងចេញពីទីតាំងនោះផងដែរ។*
- ☐ ភ្ញៀវអាចយកម្ហូប និងភេសជ្ជៈផ្ទាល់ខ្លួនបាន។ អាហារនឹងត្រូវបានអនុញ្ញាតឱ្យកុម្ម៉ង់ពីក្រៅ។ ភ្ញៀវអាចពិសាអាហារ ឬភេសជ្ជៈបានតែនៅតាមទីតាំងដែលបានកំណត់នៅក្នុងមជ្ឈមណ្ឌលការពាររលកកម្តៅ។ ទីតាំងដែលបានកំណត់នេះគួរតែត្រូវបានរៀបចំឡើងដើម្បីឱ្យមានការរក្សាគម្លាតយ៉ាងតិច 6 ហ្វីតរវាងមនុស្សទាំងអស់ក្នុងបរិវេណនេះ។ ភ្ញៀវត្រូវតែរំលឹកឱ្យពាក់ម៉ាស់របស់ពួកគេ លើកលែងតែពេលពួកគេកំពុងពិសាអាហារ ឬភេសជ្ជៈយ៉ាងសកម្មប៉ុណ្ណោះ។ បន្ទាប់ពីពួកគេបានពិសាអាហារ ឬភេសជ្ជៈរួចរាល់ហើយ ពួកគេត្រូវតែពាក់ម៉ាស់របស់ពួកគេភ្លាមៗ។ ទីតាំងនេះមិនអាចរក្សាទុក ឬទុកអាហារឬភេសជ្ជៈរបស់ភ្ញៀវក្នុងទូទឹកកកបានទេ។ មិនអនុញ្ញាតឱ្យចែករំលែកអាហារឡើយ។
  **ករណីលើកលែង៖** សមាជិកក្រុមគ្រួសារ ឬនៅក្នុងផ្ទះតែមួយ។
  - → *បុគ្គលិកនឹងណែនាំភ្ញៀវទាំងឡាយថា ការពិសាអាហារ និងភេសជ្ជៈអាចធ្វើទៅបានតែនៅក្នុងទីតាំងពិសាអាហារដែលបានកំណត់នៅក្នុងទីតាំងនោះប៉ុណ្ណោះ។*
  - → *បុគ្គលិកនឹងរំលឹកភ្ញៀវទាំងឡាយថា ម៉ាស់អាចត្រូវដោះចេញបានរយៈពេលខ្លីខណៈពេលដែលភ្ញៀវកំពុងពិសាអាហារ ឬភេសជ្ជៈ ប៉ុន្តែត្រូវពាក់វិញភ្លាមៗនៅពេលបុគ្គលនោះបានពិសាអាហារ ឬភេសជ្ជៈរួចរាល់ហើយ។*
  - → *បុគ្គលិកនឹងណែនាំដល់ភ្ញៀវណាដែលស្នើសុំការរក្សាទុកអាហារ ឬភេសជ្ជៈថា ការស្នើនេះមិនត្រូវបានអនុញ្ញាតឡើយ។*
  - → *បុគ្គលិកនឹងស្នើសុំឱ្យមនុស្សគ្រប់រូបឱ្យបញ្ឈប់ការចែករំលែកអាហារដោយមិនត្រឹមត្រូវ។*

# ឧបសម្ព័ន្ធ A៖
# កំណត់ហេតុដោយស្ម័គ្រចិត្តរបស់ភ្ញៀវនៃមជ្ឈមណ្ឌលការពាររលកកម្តៅ

ឈ្មោះមជ្ឈមណ្ឌលការពាររលកកម្តៅ៖ ______________________________
អាសយដ្ឋានមជ្ឈមណ្ឌលការពាររលកកម្តៅ៖ ______________________________
កាលបរិច្ឆេទថ្ងៃនេះ៖ ______________________________

| ឈ្មោះ | លេខទូរស័ព្ទ |
|---|---|
| (1) | |
| (2) | |
| (3) | |
| (4) | |
| (5) | |
| (6) | |
| (7) | |
| (8) | |
| (9) | |
| (10) | |
| (11) | |
| (12) | |
| (13) | |
| (14) | |
| (15) | |
| (16) | |
| (17) | |
| (18) | |
| (19) | |
| (20) | |
| (21) | |
| (22) | |
| (23) | |
| (24) | |

| ឈ្មោះ | លេខទូរស័ព្ទ |
| --- | --- |
| (25) | |
| (26) | |
| (27) | |
| (28) | |
| (29) | |
| (30) | |
| (31) | |
| (32) | |
| (33) | |
| (34) | |
| (35) | |
| (36) | |
| (37) | |
| (38) | |
| (39) | |
| (40) | |
| (41) | |
| (42) | |
| (43) | |
| (44) | |
| (45) | |
| (46) | |
| (47) | |
| (48) | |
| (49) | |
| (50) | |
| (51) | |
| (52) | |
| (53) | |

| ឈ្មោះ | លេខទូរស័ព្ទ |
|---|---|
| (54) | |
| (55) | |
| (56) | |
| (57) | |
| (58) | |
| (59) | |
| (60) | |
| (61) | |
| (62) | |
| (63) | |
| (64) | |
| (65) | |
| (66) | |
| (67) | |
| (68) | |
| (69) | |
| (70) | |
| (71) | |
| (72) | |
| (73) | |
| (74) | |
| (75) | |
| (76) | |
| (77) | |
| (78) | |
| (79) | |
| (80) | |

**ចំនួនសរុបថ្ងៃនេះ៖** ________________________
(សរុបពីសន្លឹកនៃការចុះឈ្មោះចូល + អ្នកដែលមិនចង់ចុះឈ្មោះចូល)